## ព្រះរាជាណាចក្រកម្ពុជា
### ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាដំបូងខេត្តកំពង់ធំ**

- សាលក្រមព្រហ្មទណ្ឌ លេខៈ ៣៩ "ផ"
  ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០២៣
- សំណុំរឿងព្រហ្មទណ្ឌ លេខៈ ៧១១
  ចុះថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០២១
- សំណុំរឿងជំនុំជម្រះ លេខៈ ៤៦
  ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០២៣

# តាងនាមប្រជារាស្ត្រខ្មែរ
# សាលាដំបូងខេត្តកំពង់ធំ

បានបើកសវនាការជាសាធារណៈ នៅសាលាដំបូងខេត្តកំពង់ធំ នាថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២៣ វេលាម៉ោង០៨ និង៣០នាទី ព្រឹក ដែលមានសមាសភាពដូចខាងក្រោម៖

**ក្រុមប្រឹក្សាជំនុំជម្រះ**

លោក [redacted] ចៅក្រមនៃសាលាដំបូងខេត្តកំពង់ធំ ជាប្រធានក្រុមប្រឹក្សា

លោក [redacted] អនុប្រធានសាលាដំបូងខេត្តកំពង់ធំ ជាចៅក្រមប្រឹក្សា

លោកស្រី [redacted] ចៅក្រមនៃសាលាដំបូងខេត្តកំពង់ធំ ជាចៅក្រមប្រឹក្សា

**តំណាងអយ្យការ**

លោក [redacted] ព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូងខេត្តកំពង់ធំ

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ក្រឡាបញ្ជីនៃសាលាដំបូងខេត្តកំពង់ធំ

**ដើម្បីជំនុំជម្រះ**

លើសំណុំរឿងព្រហ្មទណ្ឌលេខ៖ ៧១១ ចុះថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០២១ ដែលមាន៖

**<u>ជនជាប់ចោទ៖</u>**

ឈ្មោះ [redacted] យ៉ាន ភេទប្រុស អាយុ៤៥ឆ្នាំ ជាតិខ្មែរ មានទីលំនៅបច្ចុប្បន្ន [redacted] ខេត្តកំពង់ធំ ជានីតិជន

- ដីកាបង្គាប់ឲ្យនាំខ្លួនលេខ៖ ៥៩ ចុះថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០២២។

ត្រូវបានជាប់ចោទពីបទ៖ កាប់រានដីព្រៃ ឈូសឆាយដីព្រៃ ហ៊ុំព័ទ្ធកាន់កាប់ដីព្រៃដោយគ្មានលិខិតអនុញ្ញាត ប្រព្រឹត្តនៅចំណុចតំបន់អូរថាំស្រីត្រដក់ពង ភូមិទំនប់ ឃុំស្រើង ស្រុកប្រាសាទសំបូរ ខេត្តកំពង់ធំ កាលពីថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២១ តាមបញ្ញត្តិមាត្រា ៩៧ កថាខណ្ឌ១ ចំណុច៦ នៃច្បាប់ស្តីពីព្រៃឈើ។

**<u>មេធាវីការពារសិទ្ធិឱ្យជនត្រូវចោទ៖</u>**

មេធាវីឈ្មោះ [redacted] អាសយដ្ឋានភូមិផ្ទះលេខ ១៧៩ ផ្លូវលំ ភូមិត្រពាំងថ្ម្រ សង្កាត់កាកាបទី២ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ។

**១. អង្គហេតុដែលប្តឹងមកតុលាការមានដូចតទៅ**



Scanned with CamScanner

យោងតាមដីកាសន្និដ្ឋានស្ដាពរ និងដីកាបញ្ជូនរឿងទៅជំនុំជម្រះបញ្ជាក់ថា៖ កាលពីថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២១ សមត្ថកិច្ចសង្កាត់រដ្ឋបាលព្រៃឈើប្រាសាទសំបូរ សហការជាមួយក្រុមប្រឹក្សាឃុំស្រើង និងគណៈ កម្មាធិការសហគមន៍ព្រៃឈើអូរចាំស្រីត្រដក់ពង បានចុះត្រួតពិនិត្យ និងបង្ក្រាបបទល្មើសព្រៃឈើ និងសត្វព្រៃ បានប្រទះឃើញការកាប់រានព្រៃឈើ ឈូសឆាយដីព្រៃ ហ៊ុំព័ទ្ធកាន់កាប់ដីព្រៃឈើ យកធ្វើជាកម្មសិទ្ធិផ្ទាល់ខ្លួន ត្រង់ចំណុចនិយាមកា (៥១៨៨០៥-១៤១៧៣៨៤) (៥១៨៨៤៤៩-១៤១៧៤៦៣) (៥១៨៣៣៨-១៤១៧៧៥២) (៥១៨៣១៤-១៤១៧៤២៧) ដែលមានទីតាំងស្ថិតនៅតំបន់អូរចាំស្រីត្រដក់ពង ភូមិទំនប់ ឃុំស្រើង ស្រុក ប្រាសាទសំបូរ ខេត្តកំពង់ធំ ដែលមានទំហំ ០ ហិកតា ៩៩៦៦អា ដោយគ្មានលិខិតអនុញ្ញាតពីរដ្ឋបាលព្រៃឈើ។ តាមការអះអាងរបស់ប្រធានសហគមន៍ព្រៃឈើអូរចាំស្រីត្រដក់ពង បានបញ្ជាក់ថា ៖ អ្នកប្រព្រឹត្តិនៅលើដីនេះ គឺមានឈ្មោះ [redacted] យ៉ាន ដែលរស់នៅភូមិទំនប់ ឃុំស្រើង ស្រុកប្រាសាទសំបូរ ខេត្តកំពង់ធំ ហើយសមត្ថកិច្ច ក៏បានកសាងសំណុំរឿងបញ្ជូនមកតុលាការ ដើម្បីចាត់ការតាមផ្លូវច្បាប់តែម្តង ។

- បានឃើញ ដីកាសន្និដ្ឋានស្ដាពរលេខ៖ ៥១៧ ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០២២ របស់តំណាងអយ្យការអមសាលាដំបូងខេត្តកំពង់ធំ។

- បានឃើញ ដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ៖ ៥១៤៣ ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ ២០២២ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តកំពង់ធំ។

- បានឃើញ ដីកាសម្រេចចាត់តាំងចៅក្រមជំនុំជម្រះលេខ៖ ២០២២ខែតុលា ឆ្នាំ ០៥ចុះថ្ងៃទី ៥៤៣ របស់ប្រធានសាលាដំបូងខេត្តកំពង់ធំ។

**២. ពេលសវនាការ**

- **ជនជាប់ចោទឈ្មោះ** [redacted] **យ៉ាន ឆ្លើយនៅពេលសវនាការថា៖** មិនបានបង្ហាញខ្លួនក្នុងអង្គសវនាការទេ ដោយគ្មានមូលហេតុ ទោះបីជាតុលាការបានធ្វើការកោះហៅតាមនីតិវិធី។

- **តាមអំណានចម្លើយមន្ត្រីនគរបាលយុត្តិធម៌ ឈ្មោះ** [redacted] **រ៉ាឌី ឆ្លើយពេលសវនាការថា៖** កាលពីថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២១ សមត្ថកិច្ចសង្កាត់រដ្ឋបាលព្រៃឈើប្រាសាទសំបូរ សហការជាមួយក្រុមប្រឹក្សាឃុំស្រើង និងគណៈ កម្មាធិការសហគមន៍ព្រៃឈើអូរចាំស្រីត្រដក់ពង បានចុះត្រួតពិនិត្យ និងបង្ក្រាបបទល្មើសព្រៃឈើ និងសត្វព្រៃសហគមន៍អូរចាំស្រីត្រដក់ពង ក្នុងភូមិសាស្ត្រភូមិទំនប់ ឃុំស្រើង ស្រុកប្រាសាទសំបូរ ខេត្តកំពង់ធំ ដោយទទួលបានលទ្ធផល៖ នៅពេលមកដល់ចំណុចនិយាមកា (៥១៨៨០៥-១៤១៧៣៨៤) (៥១៨៨៤៤៩-១៤១៧៤៦៣) (៥១៨៣៣៨-១៤១៧៧៥២) (៥១៨៣១៤-១៤១៧៤២៧) ក្នុងភូមិសាស្ត្រខាងលើ មានការកាប់ រានដីព្រៃ ចំនួន ១កន្លែង មានទំហំផ្ទៃដី ០ហិកតា ៩៩៦៦អា ដោយគ្មានលិខិតអនុញ្ញាត ដោយជនល្មើសពុំមាន នៅកន្លែងកើតហេតុ ។

- **វត្ថុតាងបានលើកយកមកសំអាងក្នុងសវនាការ៖** កំណត់ហេតុដកហូត ឃាត់ទុកវត្ថុតាងបណ្តោះអាសន្ន ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២១ ដែលមាន៖ ១.ដីព្រៃឈើទំហំ ០,៩៩៦៦ ហិកតា និងកំណត់ហេតុបទល្មើសជាក់ស្តែង៖ ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២១ ដែលមាន៖ ១.ដីព្រៃទំហំ ០,៩៩៦៦ ហិកតា ទទួលរងការកាប់រាន ២.ឈ្មោះ [redacted] យ៉ាន មិននៅកន្លែងកើតហេតុទេ តែលោក [redacted] ហ៊ុយ ប្រធានសហគមន៍ព្រៃឈើ អូរចាំស្រីត្រដក់ពង បានបញ្ជាក់ថា ឈ្មោះ [redacted] យ៉ាន ជាអ្នកកាប់រានដីព្រៃឈើ របស់សង្កាត់រដ្ឋបាលព្រៃឈើ ប្រាសាទសំបូរ នៃខណ្ឌរដ្ឋបាលព្រៃឈើកំពង់ធំ ។

- តាមរបាយការណ៍សំយោគរបស់មន្ត្រីនគបាលយុត្តធម៌ ២០៥ ចុះថ្ងៃទី០៨ ខែតុលា ឆ្នាំ២០២១ របស់ផ្នែករដ្ឋបាលព្រៃឈើសណ្តាន់ នៃខណ្ឌរដ្ឋបាលព្រៃឈើកំពង់ធំ ។

- តំណាងអយ្យការធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំថា៖ ឆ្លងកាត់ការពិភាក្សាដេញដោលនាពេលសវនាការ ក្រោយពីបានស្តាប់អំណានចម្លើយរបស់មន្ត្រីនគរបាលយុត្តិធម៌ និង ពិនិត្យភស្តុតានានា ឃើញថាជនជាប់ចោទពិតជាបានប្រព្រឹត្តដូចការចោទប្រកាន់របស់តំណាងអយ្យការមែន ដូចនេះតំណាងអយ្យការស្នើសុំតំកល់ដីកាសន្និដ្ឋានស្ថាពរលេខ ៥១៧ ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០២២ របស់អយ្យការអមសាលាដំបូងខេត្តកំពង់ធំដដែល។

- សំដីចុងក្រោយរបស់ជនជាប់ចោទ ឈ្មោះ យួន យ៉ាន អវត្តមានក្នុងសវនាការ។

- ក្រោយពីបានស្តាប់អំណានចម្លើយរបស់មន្ត្រីនគរបាលយុត្តិធម៌
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានតំណាងអយ្យការ
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានមេធាវីការពារជនជាប់ចោទ
- ក្រោយពីបានពិនិត្យភស្តុតាងនានាក្នុងសំណុំរឿង

## ៣.សំអាងហេតុ

**ក្រោយពីបានពិចារណាលើសេចក្តីសន្និដ្ឋានរបស់ភាគី ភស្តុតាង និងឯកសារនានាក្នុងសំណុំរឿង សាលាដំបូងខេត្តកំពង់ធំ៖**

១. យល់ឃើញថា៖ តុលាការធ្វើការជំនុំជម្រះលើជនជាប់ចោទឈ្មោះ [redacted] យ៉ាន ភេទប្រុស អាយុ ៤៥ឆ្នាំ (សវតាជាតិខាងលើ) ដែលបានប្រព្រឹត្តអំពើដែលបណ្តាលឱ្យមានព្យសនកម្មកើតឡើង កាលពីថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២១ នៅចំណុចតំបន់អូរចាំស្រីត្រដក់ពង ភូមិទំនប់ ឃុំស្រើង ស្រុកប្រាសាទសំបូរ ខេត្តកំពង់ធំ ត្រូវបានជាប់ចោទពីបទ៖ កាប់រានដីព្រៃ ឈូសឆាយដីព្រៃ ហ៊ុំព័ទ្ធកាន់កាប់ដីព្រៃដោយគ្មានលិខិតអនុញ្ញាត តាមមាត្រា ៩៧ កថាខណ្ឌ១ ចំណុច៦ នៃច្បាប់ស្តីពីព្រៃឈើ ។

២ .យល់ឃើញថា: តាមការសួរដេញដោលនាពេលសវនាការបានបញ្ជាក់ថា ជនជាប់ចោទ យួន យ៉ាន ភេទប្រុស មិនបានរកភស្តុតាងមកដោះបន្ទុកចំពោះការប្រព្រឹត្តអំពើ កាប់រានដីព្រៃ ឈូសឆាយដីព្រៃ ហ៊ុំព័ទ្ធ កាន់កាប់ដីព្រៃដោយគ្មានលិខិតអនុញ្ញាត។

ផ្ទុយទៅវិញ អំណានចម្លើយមន្ត្រីនគរបាលយុត្តិធម៌ឈ្មោះ [redacted] វ៉ាន់នី បានបញ្ជាក់បន្ទាប់ពេលកើតហេតុ កាលពីថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២១ សមត្ថកិច្ចសង្កាត់រដ្ឋបាលព្រៃឈើប្រាសាទសំបូរ សហការជាមួយក្រុម ប្រឹក្សាឃុំស្រើង និងគណៈកម្មាធិកាសហគមន៍ព្រៃឈើអូរចាំស្រីត្រដក់ពង បានចុះត្រួតពិនិត្យ និងបង្ក្រាប បទល្មើសព្រៃឈើ និងសត្វព្រៃសហគមន៍អូរចាំស្រីត្រដក់ពង ក្នុងភូមិសាស្ត្រភូមិទំនប់ ឃុំស្រើង ស្រុកប្រាសាទសំបូរ ខេត្តកំពង់ធំ ដោយទទួលបានលទ្ធផល៖ នៅពេលមកដល់ចំណុចនិយាមកា (៥១៨៨០៥-១៤១៧៣៨៤) (៥១៨៨៤៩-១៤១៧៤៦៣) (៥១៨៣៣៨-១៤១៧៧៥២) (៥១៨៣១៤-១៤១៧៤២៧) ក្នុងភូមិសាស្ត្រ ខាងលើមានការកាប់រានដីព្រៃ ចំនួន០១កន្លែង មានទំហំផ្ទៃដី ០ហិកតា ៩៩៦៦អា ដោយគ្មានលិខិតអនុញ្ញាត ដោយជនល្មើសពុំមាននៅកន្លែងកើតហេតុ ។

ម្យ៉ាងទៀត តាមការបញ្ជាក់នៅក្នុងកំណត់ហេតុបទល្មើសជាក់ស្តែងរបស់លោក [redacted] ហ៊ុយ ប្រធានសហគមន៍ព្រៃឈើ អូរចាំស្រីត្រដក់ពង និងភស្តុតាង ដែលធ្វើឱ្យតុលាការជឿជាក់ថា៖ កាប់រានដីព្រៃ ចំនួន ១ កន្លែង មានទំហំផ្ទៃដី ០ហិកតា ៩៩៦៦អា ក្នុងសហគមន៍អូរចាំស្រីត្រដក់ពង ក្នុងភូមិសាស្ត្រភូមិទំនប់ ឃុំស្រើង ស្រុកប្រាសាទសំបូរ ខេត្តកំពង់ធំ ដែលមានឈ្មោះ [redacted] យ៉ាន ជាអ្នកកាប់រានដីព្រៃឈើដោយគ្មានលិខិត អនុញ្ញាតពីរដ្ឋបាលព្រៃឈើ ។

៣. យល់ឃើញថា: តាមការសួរដេញដោល មានមន្ត្រីនគរបាលយុត្តិធម៌ បានបញ្ជាក់ថា ជនជាប់ចោទ បានធ្វើសកម្មភាពដោយ៖ កាលពីថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២១ សមត្ថកិច្ចសង្កាត់រដ្ឋបាលព្រៃឈើ



Scanned with CamScanner

ប្រាសាទ សំបូរ សហការជាមួយក្រុម ប្រឹក្សាឃុំស្រើង និងគណៈកម្មាធិការសហគមន៍ព្រៃឈើអូរចាំស្រី ត្រដក់ពង បានចុះ ត្រួតពិនិត្យ និងបង្ក្រាប បទល្មើសព្រៃឈើ និងសត្វព្រៃសហគមន៍អូរចាំស្រីត្រដក់ពង ក្នុងភូមិសាស្ត្រភូមិទំនប់ ឃុំស្រើង ស្រុកប្រាសាទ សំបូរ ខេត្តកំពង់ធំ ដោយទទួលបានលទ្ធផល៖ នៅពេលមកដល់ចំណុចនិយាមកា (៥១៨៨០៥-១៤១៧៣៩៤) (៥១៨៨៤៤៩-១៤១៧៤៦៣) (៥១៨៣៣៨-១៤១៧៧៥២) (៥១៨៣១៤-១៤១៧៤២៧) ក្នុងភូមិសាស្ត្រ ខាងលើមានការកាប់រានដីព្រៃ ចំនួន ១កន្លែង មានទំហំផ្ទៃដី ០ ហិកតា ៩៩៦៦អា ដោយគ្មានលិខិតអនុញ្ញាត ដោយជនល្មើសពុំមាននៅកន្លែងកើតហេតុ ។

៤. យល់ឃើញថា: របាយការណ៍សំយោគរបស់មន្ត្រីនគបាលយុត្តធម៌ ២០៥ ចុះថ្ងៃទី០៨ ខែតុលា ឆ្នាំ២០២១ របស់ផ្នែករដ្ឋបាលព្រៃឈើសណ្តាន់ នៃខណ្ឌរដ្ឋបាលព្រៃឈើកំពង់ធំ បានបញ្ជាក់ថា មានករណីកាប់រាន ដីព្រៃ ឈូសឆាយដីព្រៃ ហ៊ុំព័ទ្ធកាន់កាប់ដីព្រៃដោយគ្មានលិខិតអនុញ្ញាត ប្រព្រឹត្តដោយជនជាប់ចោទខាងលើ។

៥. យល់ឃើញថា: កំណត់ហេតុដកហូត ឃាត់ទុកវត្ថុតាងបណ្តោះអាសន្ន ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ ២០២១ និងកំណត់ហេតុបទល្មើសជាក់ស្តែង៖ ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២១ របស់សង្កាត់រដ្ឋបាល ព្រៃឈើប្រាសាទសំបូរ នៃខណ្ឌរដ្ឋបាលព្រៃឈើកំពង់ធំ បានបង្ហាញថា ជាសម្ភារៈក្នុងការប្រព្រឹត្តបទល្មើស។

៦. យល់ឃើញថា: តំណាងអយ្យការធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំ៖ តំណាងអយ្យការស្នើសុំតម្កល់ការចោទប្រកាន់ និងសុំឱ្យតុលាការ សម្រេចផ្តន្ទាទោសជនជាប់ចោទតាមផ្លូវច្បាប់។ ចំពោះសេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ មានភាពជឿជាក់បានថា អំពើរបស់ជនជាប់ចោទ ពិតជាបានប្រព្រឹត្តដូចការចោទប្រកាន់ និងតុលាការយលស្របតាមការប្តឹងសុំនេះ។

៧. យល់ឃើញថា៖ មានពិរុទ្ធភាព និងមានភស្តុតាងនានាគ្រប់គ្រាន់ បានធ្វើឱ្យតុលាការជឿជាក់បានថា អង្គហេតុខាងលើនេះ ជនជាប់ចោទពិតជាបានប្រព្រឹត្តអំពើ កាប់រាន ដីព្រៃ ឈូសឆាយដីព្រៃ ហ៊ុំព័ទ្ធ កាន់កាប់ដីព្រៃដោយគ្មានលិខិតអនុញ្ញាត ដែលត្រូវជាប់ចោទពីបទ៖ កាប់រានដីព្រៃ ឈូសឆាយដីព្រៃ ហ៊ុំព័ទ្ធ កាន់កាប់ដីព្រៃដោយគ្មានលិខិតអនុញ្ញាត ប្រព្រឹត្តនៅចំណុចតំបន់អូរចាំស្រីត្រដក់ពង ភូមិទំនប់ ឃុំស្រើង ស្រុកប្រាសាទសំបូរ ខេត្តកំពង់ធំ កាលពីថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២១ តាមបញ្ញត្តិមាត្រា ៩៧ កថាខណ្ឌ១ ចំណុច ៦ នៃច្បាប់ស្តីពីព្រៃឈើ។

៨. យល់ឃើញថា៖ អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] យ៉ាន ដែលធ្វើសកម្មភាពខាងលើ បានស្តែងចេញមកខាងក្រៅ ហើយក៏មានចេតនាក្នុងការប្រព្រឹត្ត ដោយអំពើនេះវាធ្វើឱ្យប៉ះពាល់ដល់របៀបរៀបរយសណ្តាប់ធ្នាប់សាធារណៈ និងខុសច្បាប់រដ្ឋជាធរមាន តុលាការសម្រេចពីការផ្តន្ទាទោសតាមគោលការណ៍ឯកត្តកម្មនៃការទទួលខុសត្រូវព្រហ្មទណ្ឌតាមតាមមាត្រា៤ និងមាត្រា ៩៦ នៃក្រមព្រហ្មទណ្ឌ។

៩. យល់ឃើញថា៖ ជនជាប់ចោទឈ្មោះ [redacted] យ៉ាន គ្រប់ដំណាក់កាលនៃការស៊ើបអង្កេត ស៊ើបសួរ និងជំនុំជម្រះ តុលាការបានចាត់តាមនីតិវិធី ដើម្បីរក្សាសិទ្ធិឱ្យ ជនជាប់ចោទ ក្នុងការបង្ហាញការពិត និងតទល់ចំពោះការចោទប្រកាន់នានា តែ ជនត្រូវចោទ នៅបន្តអវត្តមាន និងបានគេចវេសមិនបានចូលខ្លួនមកនៅគ្រប់ដំណាក់កាល។ ម្យ៉ាងវិញទៀត ដើម្បីធានារបៀបរៀបរយសណ្តាប់ធ្នាប់សាធារណៈក្នុងសង្គម និងអនុវត្តច្បាប់រដ្ឋជាធរមាន បទល្មើសដែលចោទប្រកាន់លើជនជាប់ចោទមានកំរិត ០១ ឆ្នាំ តុលាការធ្វើការសម្រេចអោយចាប់ខ្លួន និងឃុំខ្លួនជនជាប់ចោទតាមមាត្រា ៣៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

១០. យល់ឃើញថា៖ វត្ថុដែលចាប់យក តាមកំណត់ហេតុដកហូត ឃាត់ទុកវត្ថុតាងបណ្តោះអាសន្ន ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២១ របស់ផ្នែករដ្ឋបាលព្រៃឈើប្រាសាទសំបូរ នៃខណ្ឌរដ្ឋបាលព្រៃឈើកំពង់ធំ ដែលមាន៖ ១.ដីព្រៃឈើទំហំ០,៩៩៦៦ហិកតា របស់រដ្ឋតុលាការធ្វើសម្រេចពីការរឹបអូសវត្ថុតាងតាមច្បាប់។



Scanned with CamScanner

## ៤.សេចក្តីសម្រេច

**តាមសំអាងហេតុ និងក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ**

**សាលាដំបូងខេត្តកំពង់ធំសម្រេច ÷**

**១. ផ្តន្ទាទោសលើ៖**

ជនជាប់ចោទឈ្មោះ [redacted] យ៉ាន ភេទប្រុស អាយុ៤៥ឆ្នាំ (សវតាជាតិខាងលើ) ដាក់ពន្ធនាគារកំណត់ 05 (ប្រាំ) ឆ្នាំ ជាប់ចោទពីបទ កាប់រានដីព្រៃ ឈូសឆាយដីព្រៃ ហ៊ុំព័ទ្ធ កាន់កាប់ដីព្រៃដោយគ្មានលិខិតអនុញ្ញាត ប្រព្រឹត្តនៅចំណុច តំបន់អូរចាំស្រីត្រដក់ពង ភូមិទំនប់ ឃុំស្រើង ស្រុក ប្រាសាទសំបូរ ខេត្តកំពង់ធំ កាលពីថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២១ តាមបញ្ញត្តិមាត្រា ៩៧ កថាខណ្ឌ១ ចំណុច ៦ នៃច្បាប់ស្តីពីព្រៃឈើ។

**២. បង្គាប់អោយចាប់ខ្លួន និងឃុំខ្លួនលើ៖**

ពិរុទ្ធជន ឈ្មោះ [redacted] យ៉ាន ភេទប្រុស អាយុ៤៥ឆ្នាំ (សវតាជាតិខាងលើ) យកមកអនុវត្តទោសពន្ធនាគារ និងបង្គាប់ឲ្យប្រធានពន្ធនាគារឃុំខ្លួនពិរុទ្ធជននេះ ចាប់ពីថ្ងៃប្រកាសសាលក្រមនេះតទៅ តាមមាត្រា ៣៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

សាលក្រមនេះបានធ្វើការជំនុំជម្រះនៅថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២៣ និងបានប្រកាសជាសាធារណៈថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០២៣ កំបាំងមុខជនជាប់ចោទឈ្មោះ [redacted] យ៉ាន ។

គុណាការបើកផ្លូវប្តឹងទាស់ ប្តឹងឧទ្ធរណ៍តាមច្បាប់កំណត់។

ថ្ងៃពុធ ២កើត ខែទុតិយាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស២៥៦៧

ខេត្តកំពង់ធំ ថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០២៣

| **ក្រឡាបញ្ជីសវនាការ** | **ចៅក្រមប្រឹក្សា** | **ចៅក្រមប្រឹក្សា** | **ប្រធានក្រុមប្រឹក្សាជំនុំជម្រះ** |
|---|---|---|---|
| ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា |

[redacted]

---

**បានឃើញ**

ថ្ងៃពុធ២កើតខែទុតិយាសាឍឆ្នាំថោះបញ្ចស័កព.ស២៥៦៧

ខេត្តកំពង់ធំ ថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០២៣

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]

**បានចម្លងត្រឹមត្រូវតាមច្បាប់ដើម**

ថ្ងៃពុធ២កើតខែទុតិយាសាឍឆ្នាំថោះបញ្ចស័កព.ស២៥៦៧

ខេត្តកំពង់ធំ ថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០២៣

**ក្រឡាបញ្ជី**

[redacted]



Scanned with CamScanner